**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីថ្លែងអំណរគុណ
## ជូនចំពោះឯកឧត្តម អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍

*ឯកឧត្តមជាទីស្រឡាញ់រាប់អានដ៏ជ្រាលជ្រៅ!*

ក្នុងនាមខ្លួនខ្ញុំផ្ទាល់ និងក្រុមគ្រួសារនៃសព **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ប្រធានគណបក្សប្រជាជនកម្ពុជា ប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះឯកឧត្តម និងថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ដែលបានចូលរួមរំលែកមរណទុក្ខដ៏មហាក្រៀមក្រំក្នុងពិធីបុណ្យសព**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម**។

កាយវិការដ៏ថ្លៃថ្លាឧត្តុង្គឧត្តមរបស់ឯកឧត្តម និងថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ ពិតជាបានសបញ្ជាក់ឱ្យឃើញនូវសមានចិត្តពោរពេញដោយក្តីសោកស្តាយ ស្រណោះអាឡោះអាល័យ និងមនោសញ្ចេតនាគោរពស្រឡាញ់រាប់អានដ៏ស្មោះស្ម័គ្រ និងជ្រាលជ្រៅបំផុតចំពោះ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** ដែលធ្វើឱ្យរូបខ្ញុំ និងក្រុមគ្រួសារនៃសព គ្មានថ្ងៃនឹងបំភ្លេចបានឡើយ។

ខ្លួនខ្ញុំផ្ទាល់ និងក្រុមគ្រួសារនៃសព សូមប្រសិទ្ធពរជ័យជូនចំពោះឯកឧត្តម និងថ្នាក់ដឹកនាំ មន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សូមទទួលបានពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥

**តំណាងក្រុមគ្រួសារសព**

**ស ខេង**